**កោះសន្តិភាព** ឆ្នាំទី៤២ លេខ៦៦៩៦ ថ្ងៃពុធ ទី០៨ ខែកក្កដា ឆ្នាំ២០០៩



លោក ម៉ូក ហេង និងប្រពន្ធកូនគ្មានទីជម្រកទេ (រូបថត សហការី)

# ប្តីជាយុទ្ធជនការពារទឹកដី មេស្រុកដេញប្រពន្ធនិងកូនចេញដុតផ្ទះយកដី

ខេត្តព្រះវិហារ ៖ បាតុភាពគួរឱ្យភ្ញាក់ផ្អើលមួយ កំពុងតែធ្វើឱ្យមានការស្តីបន្ទោសទៅលើអាជ្ញាធរស្រុកសង្គមថ្មី ដែលខ្វះវិធីដោះស្រាយ បែរជាដុតបំផ្លាញលំនៅឋានទាហានមួយរូប ដែលមានតែប្រពន្ធកូនរស់នៅ ឯប្តីកំពុងកាន់កាំភ្លើងប្រឈម

មុខនឹងទាហានសៀមឈ្លានពាន នៅតំបន់ប្រាសាទព្រះវិហារជិត១ឆ្នាំមកហើយ ធ្វើឱ្យទឹកចិត្តយុទ្ធជនរូបនេះបាក់ស្រុត រហូតបោះបង់ចោលកាំភ្លើងវិលត្រឡប់មកស្តារជីវភាពគ្រួសារវិញ ។

តាមប្រភពព័ត៌មានទាក់ទិននឹងករណីនេះ ត្រូវបានរាយការណ៍មកថា យុទ្ធជនម្នាក់បានខូចចិត្ត ហើយបោះបង់កងឯកភាពសឹករងជាំក្សាន្ត ដែលបច្ចុប្បន្នឈរជើងនៅលើខ្នងភ្នំដងរែក ចំណុចបុសស្បូវ ខាងកើតប្រាសាទព្រះវិហារ ៨គីឡូម៉ែត្រ ។ យុទ្ធជនរូបនេះឈ្មោះ ម៉ូក ហេង អាយុ២៩ឆ្នាំ បានទៅឈរជើងប្រចាំការនៅតំបន់នោះជិត១ឆ្នាំហើយ គឺតាំងពីថ្ងៃទី១៥ កក្កដា ២០០៨ បន្ទាប់ពីទាហានសៀមបានចូលលុកលុយតំបន់ប្រាសាទព្រះវិហារ ។ កាលពីថ្ងៃទី១៥ មិថុនា កន្លងទៅនេះ អភិបាលស្រុកសង្គមថ្មី លោក អ៊ុង វុទ្ធី បានដឹកនាំកំលាំងប៉ូលិស និងទាហានស្រុកប្រហែល៨នាក់ កាន់កាំភ្លើងគ្រប់ដៃ ទៅសម្លុតគំរាមកំហែងប្រពន្ធ និងកូនរបស់យុទ្ធជនរូបនេះ ឱ្យចាកចេញពីលំនៅឋាន និងបានដុតផ្ទះរបស់គាត់ចោលទៀត ដោយពុំមានផ្អែកទៅលើច្បាប់ ឬក៏អនុវត្តតាមដីកាតុលាការអ្វីទេ ដោយលោកអភិបាលស្រុករូបនេះ បានចោទប្រកាន់ទៅលើយុទ្ធជន ម៉ូក ហេង ថាបានទៅសង់លំនៅឋាននៅលើដីហាមឃាត់របស់សាលាស្រុក។

យុទ្ធជន ម៉ូក ហេង មានប្រពន្ធឈ្មោះ គុយ ផានិត និងមានកូនពីរនាក់នៅក្នុងបន្ទុក ។ នៅចំពោះមុខកោះសន្តិភាព យុទ្ធជន ម៉ូក ហេង បានរៀបរាប់ប្រាប់ឱ្យដឹងពីប្រវត្តិដីរបស់គាត់ថា ដីដែលគាត់បានសង់ផ្ទះសំរាប់ឱ្យប្រពន្ធ និងកូនរស់នៅនេះ គឺបានទិញពីអ្នកភូមិជាមួយគ្នាឈ្មោះ គង់ ហាំង ជានាយកសាលាបឋមសិក្សាភូមិត្បែង ក្នុងតំលៃ ៣លានរៀល។ ចំណែកលោក គង់ ហាំង នាយកសាលាបឋមសិក្សាភូមិត្បែងបានបញ្ជាក់ថា ដីដែលគាត់លក់ទៅឱ្យឈ្មោះ ម៉ូក ហេង នោះគឺជាដីដែលគាត់បានកាន់កាប់តាំងពីឆ្នាំ១៩៨៧មក ហើយនៅពេលគាត់លក់ទៅឱ្យឈ្មោះ ម៉ូក ហេង ក្នុងឆ្នាំ២០០៧ ក៏លោក អ៊ុង វុទ្ធី អភិបាលស្រុកពុំមានបញ្ហាអ្វីដែរ។ លុះនៅឆ្នាំ២០០៨ ឈ្មោះ ម៉ូក ហេង បានសង់ផ្ទះនៅលើដីនោះ ក៏មិនមានឃើញលោកអភិបាលស្រុកទៅហាមឃាត់អ្វីទេ ទាល់តែពេល ម៉ូក ហេង ត្រូវមានភារកិច្ចទៅប្រចាំការនៅសមរភូមិមុខទើបឃើញមានបញ្ហា ។

យុទ្ធជនម៉ូក ហេង បានឱ្យដឹងដែរថា ការសង់ផ្ទះនៅលើដីរបស់គាត់នេះគឺអស់រយៈពេលជិត១ឆ្នាំមកហើយ ហើយលោក អ៊ុង វុទ្ធី អភិបាលស្រុកក៏ពុំដែលចេញលិខិតស្នាមអ្វីថាឱ្យរុះរើទេ ទើបតែគាត់មានភារកិច្ចចេញទៅសមរភូមិ លោក អ៊ុង វុទ្ធី ក៏បាននាំកំលាំងទៅគំរាមកំហែងប្រពន្ធ និងកូនរបស់គាត់ឱ្យចុះចេញពីផ្ទះហើយដុតផ្ទះចោលតែម្តង។ បរិវេណដីដែលគាត់សង់ផ្ទះនោះក៏មិនមែនមានតែគាត់ម្នាក់ដែរ គឺមានផ្ទះអ្នករកស៊ីជាច្រើនទៀតតែលោក អ៊ុង វុទ្ធី មិនបានដុតឡើយ គឺដុតតែផ្ទះគាត់មួយប៉ុណ្ណោះ។ យុទ្ធជន ម៉ូក ហេង បានរៀបរាប់យ៉ាងកំសត់ថា បច្ចុប្បន្នគ្រួសាររបស់គាត់សូម្បីតែឆ្នាំងបាយមួយក៏មិនសល់ដែរ ត្រូវឆេះខ្ទេចខ្ទី អស់រលីង។ ម្យ៉ាងទៀតពេលរូបគាត់នៅឯសមរភូមិមុខពុំដែលឮថា លោកអភិបាលស្រុកបានមើលថែទាំជួយឧបត្ថម្ភអង្ករ១កំប៉ុង ឬថវិកា១សេនក៏គ្មានដែរ ស្រាប់តែមកដុតផ្ទះចោល

ទៀត គឺត្រង់ចំណុចនោះហើយដែលបង្ខំឱ្យរូបគាត់សំរេចចិត្តដាក់អាវុធចុះ បោះបង់សមរភូមិមួយរយៈ ដើម្បីរំលែកការឈឺចាប់របស់កូននិងប្រពន្ធដែលបាត់បង់ទីជម្រក ។



លោក ម៉ូក ហេង និងប្រពន្ធកូនគ្មានទីជម្រកទេ (រូបថត សហការី)

ចំណែកលោក អ៊ុង វុទ្ធី អភិបាលស្រុកសង្គមថ្មី បានប្រាប់អ្នកយកព័ត៌មានកោះសន្តិភាពតាមទូរស័ព្ទថា បានជាលោកទៅដុតផ្ទះនោះចោល ដោយសារម្ចាស់ផ្ទះរឹងទទឹងនឹងការហាមឃាត់ជាច្រើនលើកមកហើយ ព្រោះដីនោះត្រូវបានរក្សាទុក

សំរាប់ធ្វើការអភិវឌ្ឍន៏របស់សាលាស្រុកទៅថ្ងៃអនាគត។ ទោះបីជាបែបណាក្តី ការដុតបំផ្លាញផ្ទះយុទ្ធជនដែលកំពុងកាន់អាវុធការពារបូរណភាពទឹកដី វាគប្បីណាស់ថាមិនត្រូវធ្វើអ្វីទាំងកំរោលបែបនេះទេ។ ការដឹកនាំកំលាំងទៅដុតបំផ្លាញផ្ទះជនអនាធិបតេយ្យ ដើរចាប់ដីផ្តេសផ្តាសវាសមទំនងណាស់ ផ្ទុយទៅវិញការដុតនេះពិតជាទទួលបាននូវការថ្កោលទោស ព្រោះថាវាគួរតែអនុគ្រោះសំរាប់គ្រួសារយុទ្ធជនដែលកំពុងកាន់កូនខ្មោចលើសមរភូមិ ហើយបើតាមការអះអាងច្បាស់លាស់នោះ គឺជាដីទិញពីនាយកសាលាត្រឹមត្រូវណាស់ មិនបានទៅឆក់ប្លន់ដីនរណាទេ ។

យុទ្ធជន ម៉ូក ហេង ព្រមទាំងប្រពន្ធ និងកូន បានអំពាវនាវដល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវ សូមមេត្តាជួយរកយុត្តិធមិដល់គ្រួសារគាត់ផង បើពុំដូច្នោះទេគ្រួសារគាត់ដែលជាអ្នករងគ្រោះពិតជាពុំអាចទទួលបានភាពយុត្តិធមិឡើយ។ ពេលនេះយុទ្ធជន ម៉ូក ហេង ទទ្ទឹមនឹងការបាត់បង់អស់ផ្ទះសម្បែងក៏អត់ទាំងអង្ករច្រកឆ្នាំងទៀត ហើយសូមអំពាវនាវដល់សប្បុរសជន មេត្តាជួយឧបត្ថម្ភថវិកា និងសំភារៈសំរាប់ទ្រទ្រង់ក្នុងជីវភាពគ្រួសាររបស់គាត់ផង ព្រោះសព្វថ្ងៃពួកគាត់រកតែលុយទិញតង់សំរាប់ប្រក់នៅបណ្តោះអាសន្នក៏គ្មានដែរ។ ការដុតបំផ្លាញលំនៅឋានយុទ្ធជនដែលកំពុងកាន់អាវុធការពារទឹកដី គឺជាសកម្មភាពដែលមិនអាចទទួលយកបានឡើយ ព្រោះថាវិធីដោះស្រាយមានច្រើនណាស់ មិនអាចធ្វើរបៀបច្បាប់ព្រៃបែបនេះទេ ។